រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃច័ន្ទ ទី០១ ខែសីហា ឆ្នាំ២០១១

## ការទទួលពាក្យចូលរួមប្រកួតប្រជែងពីចំណេះដឹងស្តីពីច្បាប់ការងារ វគ្គ២ ចាប់ផ្តើមនៅថ្ងៃនេះ

ភ្នំពេញ ប្រទេសកម្ពុជា– *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ(ILO) ដោយសហការជាមួយវិទ្យុមហានគរ FM៩៣.៥ នឹងរៀបចំការប្រកួតប្រជែងពីចំណេះដឹងស្តីពីច្បាប់ការងារ វគ្គ២ តាមរយៈការផ្សាយតាមវិទ្យុ ដែលអនុញ្ញាតឱ្យកម្មករ-កម្មការិនីកាត់ដេរបានក្រកួតប្រជែងគ្នាពីចំណេះដឹងស្តីពីច្បាប់ការងារប្រទេសកម្ពុជា។

ការប្រកួតប្រជែងនេះនឹងផ្តល់ឱកាសដល់កម្មករ-កម្មការិនីកាត់ដេរដើម្បីបង្ហាញពីចំណេះដឹងស្តីពីច្បាប់ការងារប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមនេះគឺមានអត្ថប្រយោជន៍លើការអប់រំ និងផ្ញើរសារជាវិជ្ជមានទៅកាន់កម្មករនិយោជិតឱ្យយល់ជ្រាបថា ការយល់ដឹងអំពីច្បាប់ស្តីពីការងារប្រទេសកម្ពុជាមានសារៈសំខាន់ និងសារៈប្រយោជន៍ចំពោះជីវិតការងារប្រចាំថ្ងៃរបស់ពួកគេម្នាក់ៗ ក៏ដូចជាតស៊ូមតិដើម្បីឱ្យមានការអនុវត្តន៍ច្បាប់ការងារប្រកបដោយប្រសិទ្ធិភាពនិងលើកកម្ពស់ឧស្សាហកម្មកាត់ដេរនេះផងដែរ។

កញ្ញា Catherine Vaillancourt-Laflamme អ្នកជំនាញផ្នែកបណ្តុះបណ្តាលរបស់ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានប្រសាសន៍ថា «ការប្រកួតប្រជែងនេះនឹងមិនគ្រាន់តែជាវេទិកាមួយសម្រាប់បេក្ខជន-នារីដែលត្រូវបានជ្រើសរើសដើម្បីធ្វើការប្រកួតប្រជែងគ្នា ពាក់ព័ន្ធនឹងច្បាប់ស្តីពីការងារប៉ុណ្ណោះទេ ប៉ុន្តែការប្រកួតនេះក៏បានផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់ប្រិយមិត្តអ្នកស្តាប់មួយចំនួន ជាពិសេសកម្មករនិយោជិតកាត់ដេរ។»

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

កញ្ញា Catherine Vaillancourt-Laflamme ក៏បានបន្ថែមទៀតថា «ការយល់ដឹងអំពីច្បាប់ស្តីពីការងារឱ្យបានច្រើននោះ នឹងផ្តល់ឱ្យកម្មករនិយោជិតនូវអត្ថប្រយោជន៍បន្ថែម ហើយអ្វីដែលសំខាន់គឺថា វានឹងឈានទៅរកកិច្ចសហការដ៏ល្អនៅកន្លែងធ្វើការ និងទំនាក់ទំនងវិជ្ជាជីវៈ។ *គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ(ILO) ទទួលបាននូវភាពជោគជ័យដ៏ត្រចះត្រចង់ចំពោះការរៀបចំការប្រកួតប្រជែងនេះ កាលពីវគ្គ១។»

ការប្រកួតប្រជែងនេះគឺបើកទូលាយដល់កម្មករ-កម្មការិនី និងអតីតកម្មករ-កម្មការិនីកាត់ដេរដោយឥតគិតថ្លៃ។ ហើយការទទួលពាក្យចូលរួមប្រកួតនឹងចាប់ទទួលពីថ្ងៃនេះរហូតដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១១។ ពាក្យចូលរួមប្រកួតនឹងត្រូវបានចែកជូនដល់រោងចក្រកាត់ដេរ ហើយក៏អាចរកបាននៅការិយាល័យ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ឬតាមរយៈគេហទំព័រ www.betterfactories.org ឬនៅស្ថានីយ៍វិទ្យុមហានគរ FM៩៣.៥។

បេក្ខជន-នារីចំនួន ១២នាក់ នឹងត្រូវបានជ្រើសរើសដើម្បីប្រកួតប្រជែងគ្នានៅមុខគណៈកម្មការវិនិច្ឆ័យ នៅក្នុងការផ្សាយផ្ទាល់តាមវិទ្យុមហានគរ FM៩៣.៥។ ព្រឹត្តិការណ៍នេះនឹងធ្វើការផ្សាយផ្ទាល់រៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង២ដល់ម៉ោង៣រសៀល ដោយចាប់ផ្តើមពីថ្ងៃទី៨ ខែតុលា រហូតដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១១។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក ៖
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
ទូរស័ព្ទ៖ ០១២ ៩០ ២៩ ៩០
អ៊ីម៉េល៖ ying@ilo.org